29

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

លេខាធិការដ្ឋានរដ្ឋបាលសរុប

# កំណត់ហេតុ

## កិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ដល់មន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែតុលា ថ្ងៃទីដប់ប្រាំពីរ វេលាម៉ោងដប់បួន និងសាមសិបនាទីរសៀល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ដល់មន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោក លោកស្រី ប្រធាន អនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធានក្រុមការងារទាំង០៦ ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រីក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ បន្ទាប់មក លោកជំទាវ បានមានប្រសាសន៍ទាក់ទងនឹងគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ថា៖វាជាបញ្ហានយោបាយរបស់ប្រទេសជាតិ ដូច្នេះយើងជាមន្ត្រីរបស់រដ្ឋាភិបាល យើងត្រូវដឹងអំពីរឿងរ៉ាវរបស់រដ្ឋាភិបាល ។ ថ្ងៃនេះយើងជួបជុំគ្នាដើម្បីធ្វើការផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ដែលហៅថា "បដិវត្តន៍ពណ៌" វាជាបញ្ហានយោបាយរបស់រដ្ឋាភិបាលប្រឆាំងនឹងផែនការផ្តួលរំលំរបស់គណៈបក្សប្រឆាំង បន្ទាប់ពីរដ្ឋាភិបាលបានដឹងពីផែនការនេះទើបឈានដល់ការចាប់ខ្លួន លោក កឹម សុខា ដែលជាប្រធានគណៈបក្សសង្គ្រោះជាតិ គឺជាបទល្មើសជាក់ស្តែងក្នុងការចេញផ្សាយជាខ្សែវីដេអូឃ្លីប អំពីផែនការផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់។ ផែនការរបស់គេ គឺគេចាំតែចាប់ចំណុចខ្សោយរបស់រដ្ឋាភិបាល ដោយមានការរៀបចំជា សេនារីយ៉ូ ដោយមានការឃុបឃិតជាមួយបរទេស ដោយយកគំរូតាមប្រទេស យូហ្គោស្លាវី និងសែប៊ី ដើម្បីផ្តួលរំលំរដ្ឋាភិបាល ។ ដូច្នេះយើងជាមន្ត្រីរបស់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវជៀសវាងរាល់បញ្ហាដែលអាចធ្លាក់ក្នុងឧបាយកលរបស់គេដោយមិនដឹងខ្លួន ។ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍បន្តថា រដ្ឋាភិបាល គឺយើងទាំង

អស់គ្នា ដែលជាអ្នកបម្រើការងារជាមន្ត្រីរាជការ ត្រូវមានភាពស្មោះត្រង់ជាមួយជាតិ សាសនា ព្រះមហាក្សត្រ រដ្ឋាភិបាល និងប្រជាពលរដ្ឋ ។ ដូច្នេះយើងត្រូវដឹងអំពីទិសដៅរបស់រដ្ឋាភិបាល យើងត្រូវតែការពារអំណាចស្របច្បាប់របស់ រដ្ឋាភិបាល ក៏ដូចជាការពារគណៈបក្សប្រជាជនកម្ពុជា ។ **លោកជំទាវ** បានធ្វើការបញ្ជាក់ថា **"បដិវត្តន៍ពណ៌"** គឺសំដៅលើការប្រើប្រាស់ចលនាបដិវត្តន៍ របស់គណៈបក្សប្រឆាំង ដែលតម្រូវឲ្យមានការជ្រើសរើសយកពណ៌ណាមួយមកប្រើប្រាស់នៅក្នុងយុទ្ធសាស្ត្រប្រឆាំងរដ្ឋាភិបាល ដូចជា **"ថ្ងៃច័ន្ទ ពណ៌ខ្មៅ"** ជាដើម ហើយក៏មានប្រទេសមួយចំនួនទៀតក៏ធ្វើដូច្នេះដែរ ដោយគេជ្រើសរើសពណ៌របស់ខ្លួនសម្រាប់ធ្វើការប្រឆាំងរដ្ឋាភិបាល និងក៏មានប្រទេសមួយចំនួនទៀត គេប្រើវិធីសាស្ត្រម្យ៉ាងគឺ **"បដិវត្តន៍ផ្កាម្លិះ ឬ បដិវត្តន៍ផ្កាកូលាប..."** ។

**ឯកឧត្តម ថោង សំអាត អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានមានប្រសាសន៍ពាក់ព័ន្ធនឹងគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ថា៖ កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានកោះប្រជុំផ្ទៃក្នុងជាមួយបណ្តាអគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ចំណុះក្រសួងមហាផ្ទៃ មកផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីវិធានការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ប្រឆាំងចំពោះឧបាយកលផ្តួលរំលំរដ្ឋអំណាចស្របច្បាប់នៅកម្ពុជា ដើម្បីផ្សព្វផ្សាយបន្តដល់មន្ត្រីក្រោមឱវាទរបស់ខ្លួន ។ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ **លោក កឹម សុខា** ប្រធានគណៈបក្សសង្គ្រោះជាតិ ត្រូវបានសមត្ថកិច្ចចាប់ខ្លួននៅក្នុងភូមិគ្រឹះរបស់គាត់ ពីបទប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់តាមរយៈការធ្វើ **"បដិវត្តន៍ពណ៌"** យុទ្ធសាស្ត្រគេ គឺជ្រើសរើសកម្លាំងមហាជន ជាពិសេសយុវជន ដែលមានការថ្នាំងថ្នាក់ជាមួយរដ្ឋាភិបាល ដោយមានការគាំទ្រ និងញុះញង់ពីបរទេស និងអង្គការមួយចំនួន ។ **ឯកឧត្តម អគ្គលេខាធិការ** គ.ជ.ប.ជ មានប្រសាសន៍ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនដែលពាក់ព័ន្ធនឹងការចាប់ខ្លួនរបស់ **លោក កឹម សុខា** ដូចជា **លោក កឹម សុខា** បានចុះទៅញុះញង់ប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ស្ពឺ ដោយប្រើពាក្យថា **"ហ៊ុន សែន ត្រូវចុះចេញពីតំណែងក្រោយការបោះឆ្នោតឆ្នាំ២០១៨"** និងវីដេអូឃ្លីបបង្ហាញពីការញុះញង់ និងការរៀបចំគម្រោងរយៈពេលវែងក្នុងការផ្តួលរំលំ រដ្ឋាភិបាលស្របច្បាប់ ដោយមានការឃុបឃិតពីបរទេស ក៏ដូចជាភស្តុតាងមួយចំនួនទៀតផងដែរ ។ **ឯកឧត្តម** មានប្រសាសន៍បន្តថា យើងមានភស្តុតាងគ្រប់គ្រាន់ និងរឹងមាំ ដែល **កឹម សុខា** ប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល ដោយធ្វើ **"បដិវត្តន៍ពណ៌"** ក្នុងឆ្នាំ២០១៦ គេបានបញ្ជូនក្រុមយុវជន និងសកម្មជន ទៅរៀននៅប្រទេស ឥណ្ឌូនេស៊ី ។ សកម្មភាពក្រោយការបោះឆ្នោតឆ្នាំ២០១៣ គាត់បានធ្វើការបដិសេធមិនទទួលស្គាល់ចំពោះលទ្ធផលបោះឆ្នោត គេញុះញុងប្រមូលផ្តុំក្រុមសកម្មជន ក្រុមយុវជន ដែលមកពីតាមបណ្តាខេត្តនៅទីលានប្រជាធិបតេយ្យ ស្ពានអាកាសស្ទឹងមានជ័យ ស្ពានអាកាសក្បាលថ្នល់ ផ្លូវវែងស្រែងជាដើម រហូតដល់កើតមានអំពើហិង្សា ដុតបំផ្លាញទ្រព្យសម្បត្តិរដ្ឋ ទ្រព្យសម្បត្តិឯកជន ក៏ដូចជាបង្កឲ្យមានគ្រោះថ្នាក់ដល់សមត្ថកិច្ច និងប្រជាពលរដ្ឋស្លូតត្រង់នៅទីនោះ និងកំពុងធ្វើដំណើរតាមដងផ្លូវផងដែរ ។

ឯកឧត្តម អគ្គលេខាធិការ គ.ជ.ប.ជ មានប្រសាសន៍ថា ដើម្បីឆ្លើយតបនឹងរដ្ឋាភិបាល និងគុណបំណាច់របស់គណៈបក្សប្រជាជនកម្ពុជា គឺយើងជាមន្ត្រីរាជការរបស់រដ្ឋាភិបាលត្រូវមានការភ្ញាក់រលឹក ក្នុងការការពាររដ្ឋាភិបាលស្របច្បាប់ ប្តេជ្ញាចិត្តប្រឆាំងនឹងផែនការផ្តួលរំលំរបស់គណៈបក្សប្រឆាំង ទប់ស្កាត់មិនឲ្យមានការញុះញង់ដែលបង្កើតឲ្យមានហិង្សា ក្រោយការបោះឆ្នោតឆ្នាំ២០១៨ និងការពាររាល់សមិទ្ធផលនានារបស់រដ្ឋាភិបាលដែលបានខិតខំកសាង និងអភិវឌ្ឍកន្លងមក ។ ដូច្នេះចាប់ពីថ្ងៃផ្សព្វផ្សាយគោលការណ៍ខាងលើនេះរួច សូមលេខាធិការដ្ឋានរដ្ឋបាលសរុប ធ្វើការបែងចែកវេនប្រចាំការ (ចំណុចខ្ពស់) របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចាប់ពីថ្នាក់អគ្គលេខាធិការរង រហូតដល់មន្ត្រី (២៤ម៉ោង លើ២៤ម៉ោង) រហូតដល់បញ្ចប់ នៃការបោះឆ្នោតឆ្នាំ២០១៨ ។

ចុងបញ្ចប់ **ឯកឧត្តម អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន** គ.ជ.ប.ជ បានផ្តាំផ្ញើដល់មន្ត្រីក្រោមឱវាទថា៖ ក្នុងនាមជាមន្ត្រីរបស់រដ្ឋាភិបាលត្រូវខិតខំអនុវត្ត និងបំពេញកាតព្វកិច្ចរបស់ខ្លួនជូន ជាតិ សាសនា ព្រះមហាក្សត្រ ក៏ដូចជាជូនប្រជាពលរដ្ឋនូវសេវាសាធារណៈដោយមិនប្រកាន់និន្នាការនយោបាយឡើយ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំមួយ និងដប់ប្រាំនាទី ថ្ងៃខែឆ្នាំ ដដែល ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ២០១៧

**ប្រធានលេខាធិការដ្ឋាន**

**ឧត្តមសេនីយ៍ទោ. គង់_ពុទ្ធី**

ឯកភាព

20/10/17

**ជូ_ម៉ិនអេង**